ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្អោង-តាំងក្រសាំង
លេខ:.....៣៦២..........រ.ស.ត.ក

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើសនិស្សិតដែលមានចំណាចធ្វើកម្មសិក្សានៅរដ្ឋាករទឹកស្អោង-តាំងក្រសាំង

រដ្ឋាករទឹកស្អោង-តាំងក្រសាំងត្រូវការជ្រើសរើសនិស្សិតដែលជិតបញ្ចប់ ឬបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដើម្បីទទួលបានឱកាសធ្វើកម្មសិក្សារយៈពេល ០៣ ខែ នៅរដ្ឋាករទឹកស្អោង-តាំងក្រសាំងចំនួន ០២ រូប ដែលមាន ០២ ផ្នែក ដូចខាងក្រោម៖

| | |
|---|---|
| ១. ការងារផ្នែកវិភាគគុណភាពទឹក | ០១ រូប |
| ២. អគ្គិសនី | ០១ រូប |

បេក្ខជន បេក្ខនារី ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- បេក្ខជន បេក្ខនារី ត្រូវជានិស្សិតឆ្នាំទី៤ឡើង ឬបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងបានសិក្សាលើមុខវិជ្ជាណាមួយ ឬមុខវិជ្ជាប្រហាក់ប្រហែលនៃការងារណាមួយពាក់ព័ន្ធនឹងផ្នែកទាំង២ខាងលើ
- អាចប្រើប្រាស់កុំព្យូទ័របាន (កម្រិតមូលដ្ឋាន ដូចជា៖ Word, excel.......)
- ឧស្សាហ៍ ព្យាយាម អំណត់ ស្មោះត្រង់ និងទទួលខុសត្រូវខ្ពស់
- មានភាពរួសរាយរាក់ទាក់ សាមគ្គីភាព និងមានសីលធម៌

បេក្ខជន បេក្ខនារី ដែលមានចំណាប់អារម្មណ៍សូមមកដាក់ប្រវត្តិរូប (មានបិទរូបថត) នៅរដ្ឋាករទឹកស្អោង-តាំងក្រសាំង ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

- ទីកន្លែងទទួលពាក្យ៖ រដ្ឋាករទឹកស្អោង-តាំងក្រសាំង (ការិយាល័យរដ្ឋបាល) ដែលមានអាសយដ្ឋានស្ថិតនៅៈ ផ្លូវជាតិលេខ ០៦ ភូមិឈើទាល ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ។
- ម៉ោងធ្វើការ៖ ចាប់ពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ - ព្រឹកចាប់ពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១:៣០ នាទី
  - រសៀលចាប់ពីម៉ោង១៣:៣០ នាទី ដល់ម៉ោង ១៧:៣០ នាទី
- កាលបរិច្ឆេទនៃការឈប់ទទួលពាក្យ៖ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥

**បញ្ជាក់៖**

- បេក្ខនារី និងជនមានពិការភាពត្រូវបានលើកទឹកចិត្ត និងផ្ដល់អាទិភាពសម្រាប់ការជ្រើសរើសនេះ។
- បេក្ខជន បេក្ខនារី ដែលត្រូវបានជ្រើសរើសដើម្បីធ្វើកម្មសិក្សា នឹងទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាករទឹកស្អោង-តាំងក្រសាំងក្នុងរយៈពេលនៃកម្មសិក្សា។
- ព័ត៌មានបន្ថែម បេក្ខជន បេក្ខនារទីអាចទំនាក់ទំនងនៅផ្នែករដ្ឋបាលនៃរដ្ឋាករទឹកទឹកស្អោង-តាំងក្រសាំង ឬអាចទំនាក់ទំនងតាមរយៈលេខ/តេឡេក្រាម៖ 012 901 980។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែ ស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ស្ទោង ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០២៥
អគ្គនាយក

ឡេង_សុភា